ISSN 1560-7615 / ISBN 978-99950-52-06-5

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

# ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ២០ លេខ ២ ខែមិថុនា ២០១៦ តម្លៃ ១.៥០០៛

# វិទ្យាល័យនៅកម្ពុជា៖ កង្វះខាតការស្រាវជ្រាវ


## ខ្លឹមសារសង្ខេប

ការឡើងឋានៈជាប្រទេស មានប្រាក់ចំណូលមធ្យមកម្រិតទាប ជាដំណាក់កាលដ៏សំខាន់មួយ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ច នៅកម្ពុជា។ ការផ្លាស់ប្តូរគោលនយោបាយ ដែលធ្លាប់តែផ្តោតលើការកាត់បន្ថយភាពក្រីក្រ ទៅផ្តោតជាសំខាន់លើកំណើនសម្រាប់ទាំងអស់គ្នា ប្រកបដោយចីរភាពដោយមានកម្លាំងជំរុញពីសហគ្រាសបង្កើតតម្លៃបន្ថែមខ្ពស់ បញ្ជាក់ឱ្យឃើញថា ការអប់រំ និងបណ្តុះបណ្តាលជំនាញ កាន់តែមានសារៈសំខាន់ឡើង។ ដោយសារចំណែកថវិកាជាតិសម្រាប់វិស័យអប់រំកាន់តែកើនឡើង ហើយការប្តេជ្ញាចិត្តផ្នែកនយោបាយក៏កាន់តែខ្ពស់ បូករួមទាំងជំនួយផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុជាបន្តបន្ទាប់ពីដៃគូអភិវឌ្ឍន៍ផង កម្ពុជានាបច្ចុប្បន្នបានឈានដល់ពាក់កណ្តាលផ្លូវនៃ ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤-១៨ ដែលមានគោលដៅធានាឲ្យបាននូវការអប់រំមួយមានគុណភាពល្អ ហើយមនុស្សគ្រប់គ្នាមានលទ្ធភាពទទួលបានការអប់រំនេះយ៉ាងងាយស្រួល។ ទោះយ៉ាងនេះក្តី បញ្ហាប្រឈមនៅតែមានច្រើននៅឡើយ។ ការសិក្សាជាក់ស្តែងមួយចំនួនពីការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ ព្រមទាំងព័ត៌មានលំអិតពីសន្និបាតអប់រំឆ្នាំ២០១៦ បានបង្ហាញពីកង្វះខាតការស្រាវជ្រាវលើបួនចំណុចសំខាន់ៗ៖ ១) គុណភាពនៃការអប់រំ ២) កម្មវិធីសិក្សា និងវិធីសាស្រ្តបង្រៀន ៣) ការបង្រៀនឯកជន ឬការបង្រៀនគួរ និង ៤)ការអភិវឌ្ឍខ្លួន សុខភាព និងសីលធម៌របស់សិស្ស។





*ការអប់រំ និងការបណ្តុះបណ្តាលជំនាញ មានសារៈសំខាន់ខ្លាំងណាស់។
ខេត្តព្រៃវែង ខែកុម្ភៈ ឆ្នាំ២០១៦*

## សេចក្តីផ្តើម

ប្រព័ន្ធអប់រំទូទៅនៅកម្ពុជា ចែកចេញជា៤ដំណាក់កាល៖ មត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សា (បឋមភូមិ និងទុតិយភូមិ) និងឧត្តមសិក្សា។ ក្រោយបញ្ចប់ថ្នាក់មធ្យមសិក្សាបឋមភូមិ (អនុវិទ្យាល័យ) សិស្សអាចជ្រើសរើសបន្តការសិក្សាថ្នាក់មធ្យមសិក្សាទុតិយភូមិ (វិទ្យាល័យ) ឬអាចចូលរៀនក្នុងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈរបស់ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និង ក្រសួងអប់រំ យុវជន និងកីឡា នៅតាមបណ្តាខេត្តមួយចំនួន។

ចក្ខុវិស័យអប់រំរយៈពេលវែង គឺធ្វើឲ្យគុណភាពអប់រំគ្រប់កម្រិតបានកាន់តែល្អប្រសើរឡើង។ រាជរដ្ឋាភិបាលបានបង្កើនថវិកាជាតិសម្រាប់វិស័យអប់រំជាបន្តបន្ទាប់ ពី ១៦% នៃចំណាយសាធារណៈសរុបក្នុងឆ្នាំ២០១២ ដល់ ១៧% ក្នុងឆ្នាំ២០១៥ និងជាង ១៨,៥% ក្នុងឆ្នាំ២០១៦ (MOEYS 2016)។ ដោយប្រៀបធៀបទៅនឹងវត្ថុបំណងទាំងបីនៃ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP) ឆ្នាំ២០១៤-១៨ ពោលគឺ លទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ គុណភាពនិងភាពសមស្របនឹងតម្រូវការនៃ

---

អត្ថបទនេះ រៀបចំដោយ សូ ភីណា អ្នកស្រាវជ្រាវ និង Ji-Hyun Kang អ្នកស្រាវជ្រាវស្ម័គ្រចិត្ត (មកពី KOICA) នៃផ្នែកអប់រំ នៃវិទ្យាស្ថាន CDRI។ សូមយោងឯកសារនេះថា៖ So Phina and Ji-Hyun Kang. 2016. “Upper Secondary School in Cambodia: Research Gaps.” Cambodia Development Review 20(2): 1-5។ ភ្នំពេញ វិទ្យាស្ថាន CDRI។

## មាតិកា


វិទ្យាល័យនៅកម្ពុជា៖ កង្វះខាតការស្រាវជ្រាវ ........................ ១
អភិបាលកិច្ចទឹកសម្រាប់ភាពធន់នឹងអាកាសធាតុ៖
លទ្ធផលសិក្សាពីថ្នាក់មូលដ្ឋាន និងថ្នាក់ក្រោមជាតិ............ ៦
ប្រព័ន្ធធានាសុវត្ថិភាពសង្គម និងបរិស្ថាន៖ បទពិសោធន៍
ទទួលបានពីគម្រោងសាកល្បងនៃកម្មវិធីរេដ+ ............... ១០
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស ..................... ១៥
— ស្ថានភាពក្នុងប្រទេស........................ ១៧
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI ....................................... ២៤

រូបភាព១៖ រចនាសម្ព័ន្ធនៃប្រព័ន្ធអប់រំនៅកម្ពុជា




ប្រភព៖ ADPC 2008

ការបង្រៀននិងការរៀន និង ការកែលំអការដឹកនាំនិងគ្រប់គ្រងលើវិស័យអប់រំនោះ សន្និបាតអប់រំឆ្នាំ២០១៦ បានរាយការណ៍ពីការរីកចម្រើនមួយចំនួន នៅកម្រិតមធ្យមសិក្សាក្នុងសូចនាករស្នូលដូចខាងក្រោម (តារាង១)។

ទោះបីមានការប្ដេជ្ញាចិត្តពីរាជរដ្ឋាភិបាល និងជំនួយគាំទ្រផ្នែកហិរញ្ញវត្ថុនិងបច្ចេកទេសពីដៃគូអភិវឌ្ឍន៍នានាក្ដី ឧបសគ្គធំៗមួយចំនួននៅតែមាន។ សន្និបាតអប់រំឆ្នាំ២០១៦ បានទទួលស្គាល់ថា មានបញ្ហាប្រឈម១១មុខ ចាប់ពី បញ្ហាផ្នែកគ្រប់គ្រងរដ្ឋបាលនិងបុគ្គលិក រហូតដល់ បញ្ហាផ្នែកហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុនិងផែនការ ការអភិវឌ្ឍកម្មវិធីសិក្សា និងការធានាគុណភាពអប់រំ។ ម៉្យាងទៀត អត្រាដ៏ខ្ពស់នៃសិស្សធ្លាក់ការប្រលងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ២០១៤-១៥ បានបង្ហាញថា ការអប់រំថ្នាក់មធ្យមសិក្សា កំពុងតែខ្វះគុណភាពជាខ្លាំង។ ជាក់ស្ដែង ក្រសួងអប់រំ យុវជន និងកីឡា (MOEYS 2016) បានរាយការណ៍ពីការល្អប្រសើរឡើងតែបន្តិចបន្តួចក្នុងអត្រាចុះឈ្មោះចូលរៀនថ្នាក់មធ្យមសិក្សាទុតិយភូមិ គុណភាពនៃការរៀន និងអត្រាត្រួតថ្នាក់ រីឯអត្រាសិស្សបោះបង់ការសិក្សានៅនឹងដដែល។

អត្ថបទនេះ ពិនិត្យលើការសិក្សាដែលផ្អែកលើការពិសោធន៍ជាក់ស្ដែងមួយចំនួនស្ដីពី ការអប់រំថ្នាក់មធ្យមសិក្សាទុតិយភូមិនៅកម្ពុជា និងព្យាយាមកំណត់នូវចន្លោះខ្វះខាតសំខាន់ៗក្នុងការស្រាវជ្រាវ។ លទ្ធផលរកឃើញទាំងនេះអាចជួយផ្ដល់ព័ត៌មានដល់របៀបវារៈនៃការស្រាវជ្រាវថ្នាក់ជាតិ និងការកំណត់អាទិភាពក្នុងវិស័យអប់រំ ហើយក៏អាចដាក់បញ្ចូលទៅក្នុងកំណែទម្រង់វិស័យអប់រំនាពេលអនាគតដែរ។ អត្ថបទនេះចាប់ផ្ដើមឡើងតាមការ

តារាង១៖ សូចនាករស្នូលនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤-១៨

| សូចនាករស្នូល | ស្ថានភាពឆ្នាំ ២០១៣/១៤ | ស្ថានភាពឆ្នាំ ២០១៥/១៦ | គោលដៅឆ្នាំ ២០១៧/១៨ |
|---|---|---|---|
| *គោលនយោបាយ ផ្នែកទី១៖ ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌* | | | |
| ចំនួនខេត្តមានអត្រាបញ្ចប់ការអប់រំថ្នាក់អនុវិទ្យាល័យស្មើឬលើសពី ៤០% | ៧ | ៨ | ១៧ |
| *គោលនយោបាយ ផ្នែកទី២៖ លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃសេវាអប់រំ* | | | |
| អត្រាអក្ខរកម្មនៃយុវជន (១៥-២៤ឆ្នាំ) | ៩២,១% (២០១២) | ៩០,១% (២០១៤) | ៩៧,៥% |
| ការវាយតម្លៃថ្នាក់ជាតិលើការរៀនសូត្ររបស់សិស្សថ្នាក់ទី៣ ទី៦ និងទី៨ សម្រាប់ ភាសាខ្មែរ និងគណិតវិទ្យា | សិស្សថ្នាក់ទី៣ ការវាយតម្លៃ បានអនុវត្តរួច | សិស្សថ្នាក់ទី៦ លទ្ធផលវាយតម្លៃបានផ្សព្វផ្សាយរួច | សិស្សថ្នាក់ទី៨ ការវាយតម្លៃនឹងត្រូវអនុវត្ត |

ប្រភព៖ សន្និបាតអប់រំឆ្នាំ២០១៦

ពិនិត្យលើចំណុចត្រូវស្រាវជ្រាវចំនួនបួន៖ ១) គុណភាពអប់រំ និងគ្រូបង្រៀន ២) ខ្លឹមសារកម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀន ៣) ការបង្រៀនឯកជន ឬបង្រៀនគួរ និង ៤) កម្មវិធីសុខភាពសាលារៀន។ បន្ទាប់មក មានការលើកមតិពីទិសដៅសម្រាប់ការស្រាវជ្រាវនាពេលអនាគត ដោយផ្ដល់ជាសំណួរគួរស្រាវជ្រាវមួយចំនួន។

## ការសិក្សាលើឯកសារសិក្សាស្រាវជ្រាវមានស្រាប់ *គុណភាពនៃការអប់រំ និងការបង្រៀន*

ដោយសារ ការអប់រំ និងបណ្ដុះបណ្ដាលបច្ចេកទេស ដែលជាកត្តាមួយជួយសម្រួលដល់ការចូលបម្រើការងារ មានគុណភាពកាន់តែល្អប្រសើរឡើង ដូច្នេះវាក៏បង្កើតកម្លាំងពលកម្មជំនាញមានគុណវឌ្ឍិ បានកាន់តែច្រើនឡើង។ ការបង្កើនគុណភាពអប់រំគឺជាប្រធានបទស្នូលមួយ នៃការស្រាវជ្រាវក្នុងវិស័យអប់រំជាយូរណាស់មកហើយ។ អត្រាដ៏ទាបនៃការប្រឡងជាប់របស់សិស្សថ្នាក់ទី១២ ក្នុងការប្រឡងថ្នាក់ជាតិឆ្នាំ២០១៤-១៥ (២៦%) ជាលទ្ធផលមួយនៃការចាប់ផ្ដើមអនុវត្តវិធានការដ៏តឹងរឹង ដើម្បីលុបបំបាត់ការចម្លងគ្នាក្នុងពេលប្រឡង និងអំពើពុករលួយនានា ហើយវាក៏ជាភស្តុតាងច្បាស់ក្រឡែតមួយ បង្ហាញពីគុណភាពខ្សោយនៃប្រព័ន្ធអប់រំថ្នាក់មធ្យមសិក្សា (Madhur 2015)។ ដោយមើលឃើញពី តម្រូវការកិច្ចប្រឹងប្រែងពង្រឹងគុណភាពអប់រំបន្ថែមទៀត លោក Khieng, Madhur and Chhem (2015) បានស្នើឲ្យយកចិត្តទុកដាក់កាន់តែខ្លាំងលើ ការបង្កើនអត្រាចុះឈ្មោះចូលរៀន ការកាត់បន្ថយអត្រាបោះបង់ការសិក្សា ការទាក់ទាញគ្រូបង្រៀនដែលមានគុណភាព ការពង្រឹងផ្នែកគរុកោសល្យ និងការកែលំអការគ្រប់គ្រងនិងអភិបាលកិច្ចក្នុងសាលារៀន។

គុណភាពនៃប្រព័ន្ធអប់រំរបស់ប្រទេសមួយ មិនអាចនឹងប្រសើរឡើងបានដោយមិនគិតពីបញ្ហាគុណភាពគ្រូបង្រៀននោះទេ។ ការស្រាវជ្រាវពីថ្នាក់មធ្យមសិក្សាទុតិយភូមិជាច្រើន បានគូសបញ្ជាក់ពីបញ្ហាប្រឈមនៃកង្វះចំនួន និងគុណភាពគ្រូបង្រៀន (Brehm and Silova 2014; Madhur 2014; MOEYS 2016; Nou 2015; Phin 2014; You 2010)។ ទោះបីក្រសួងអប់រំ យុវជន និងកីឡា បានប្ដេជ្ញាចិត្ត និងប្រឹងប្រែងជាខ្លាំងក្នុងការពង្រឹងវិស័យអប់រំយ៉ាងណាក្ដី ក៏គ្រូបង្រៀនថ្នាក់មធ្យមសិក្សាទុតិយភូមិនៅមានកម្រិតអប់រំទាបនៅឡើយ ហើយចំនួនគ្រូនៅតាមសាលារៀនជនបទ នៅតែមានការខ្វះខាតបើប្រៀបនឹងសាលារៀននៅទីក្រុង (Nou 2015)។ កង្វះខាតគ្រូបង្រៀនមានការបណ្ដុះបណ្ដាលត្រឹមត្រូវ អាចជះឥទ្ធិពលធ្ងន់ធ្ងរទៅលើសិស្សក្រីក្រ ដែលមិនមានចំណេះដឹងគ្រប់គ្រាន់ សម្រាប់បន្តការសិក្សាថ្នាក់ឧត្ដមសិក្សា ហើយទីបំផុត ធ្លាក់ចូលក្នុងវដ្តនៃការអប់រំមានគុណភាពទាប ពីមួយជំនាន់ទៅមួយជំនាន់ (Madhur 2014)។ Un (2014) បានចង្អុលបង្ហាញថា ការអប់រំដែលមានគុណភាពខ្សោយ មិនមែនសុទ្ធតែបណ្ដាលមកពីបញ្ហាកង្វះគ្រូបង្រៀននោះទេ ប៉ុន្តែក៏អាចមកពីគុណភាពគ្រូបង្រៀនផងដែរ។ អ្នកប្រាជ្ញជាច្រើន បានបន្ថយការបន្ទោសគ្រូលើបញ្ហាគុណភាពបង្រៀន (Bray 2007; Dawson 2010) ដោយបែរទៅសង្កត់ធ្ងន់លើទំនាក់ទំនងរវាងគុណភាពគ្រូ និងជំនួយគាំទ្រពីស្ថាប័នសម្រាប់ការអភិវឌ្ឍជំនាញវិជ្ជាជីវៈ និងការរៀនសូត្របន្ថែមរបស់គ្រូ (Phin 2014)។

ចក្ខុវិស័យក្រសួងអប់រំ យុវជន និងកីឡា (MOEYS 2013) សម្រាប់គ្រូបង្រៀនមានគុណភាពខ្ពស់ បានលើកពីចំណេះដឹងជំនាញ សមត្ថភាព និងចរិតលក្ខណៈគ្រូបង្រៀន ហើយបានកំណត់ឡើងវិញនូវអត្ថន័យនៃពាក្យ "ការបង្រៀន" ថាជា ជម្រើសអាជីពដ៏មានតម្លៃ និងគួរឲ្យគោរព។ យុទ្ធសាស្ត្រថ្មីៗសម្រាប់ជ្រើសរើស និងរក្សាទុកគ្រូបង្រៀន មានដូចជា ការព្យាយាមទាក់ទាញបុគ្គលល្អៗនិងវ័យឆ្លាតជាងគេឲ្យចូលធ្វើជាគ្រូបង្រៀន ការបង្កើតមជ្ឈមណ្ឌលបណ្ដុះបណ្ដាលគ្រូបង្រៀន និងការរៀបចំឡើងវិញនូវការអប់រំគ្រូ។ Tandon and Fukao (2015) បានផ្ដល់មតិគាំទ្រឲ្យមានជាគោលនយោបាយស្រដៀងៗគ្នា ពោលគឺ ធ្វើឲ្យការបង្រៀនមានភាពទាក់ទាញ រៀបចំគ្រូបង្រៀនឲ្យកាន់តែមានប្រសិទ្ធភាព និងជំរុញឲ្យសកម្មភាពក្នុងថ្នាក់រៀនមានភាពកាន់តែប្រសើរឡើង។

ការសិក្សានានាបង្ហាញថា ការស្រាវជ្រាវមានសារៈសំខាន់ណាស់ ដើម្បីបង្កើនគុណភាពនៃការអប់រំបច្ចេកទេស និងកាត់បន្ថយកង្វះខាតជំនាញ។ ផែនការគោលសម្រាប់ការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិឆ្នាំ២០១៥-១៩ (MOEYS 2015) បានកំណត់ច្បាស់ពីតម្រូវការការស្រាវជ្រាវនៅក្នុង យុទ្ធសាស្ត្រសំដៅដាក់បញ្ចូលការអប់រំបច្ចេកទេស ទៅក្នុងថ្នាក់មធ្យមសិក្សាទុតិយភូមិ ដើម្បីជួយរៀបចំសិស្សសម្រាប់ការចូលបម្រើការងារ។ លទ្ធផលនេះ ផ្អែកលើការសិក្សាពីមុនរបស់ Va (2012) ដែលរកឃើញថា ជម្រើសការអប់រំបច្ចេកទេសនៅថ្នាក់មធ្យមសិក្សាទុតិយភូមិ បានកាត់បន្ថយកង្វះខាតជំនាញ អត្រាបោះបង់ការសិក្សា និងភាពក្រីក្រ ហើយបានលើកកម្ពស់ស្ថិរភាពសង្គម និងភាពត្រូវបានរាប់បញ្ចូលក្នុងសង្គម (inclusion)។ របាយការណ៍ទាំងពីរនេះ បានគូសបញ្ជាក់ពីបញ្ហាប្រឈមនៃ សម្ភារបរិក្ខារបច្ចេកទេសដែលមានតម្លៃខ្ពស់ និងការចំណាយដ៏ច្រើនលើការថែទាំសម្ភារទាំងនោះ ហើយបានលើកបន្ថែមថា ក្រសួងអប់រំ យុវជន និងកីឡា គួរវិនិយោគ និងពង្រីកផ្នែកជាច្រើនទៀត ជាពិសេស ការត្រួតពិនិត្យ និងការវាយតម្លៃការអប់រំដើម្បីកំណត់នូវសាលារៀន និងគ្រូដែលមានសកម្មភាពច្រើននិងល្អជាងគេ ក៏ដូចជាប្រព័ន្ធដែលទទួលបរាជ័យទាំងឡាយរបស់សាលារៀន។

### *ខ្លឹមសារកម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀន*

កម្មវិធីសិក្សា និងគរុកោសល្យល្អសមស្រប មានសារៈសំខាន់ណាស់សម្រាប់ធានាឲ្យបាននូវ គុណភាពអប់រំដែលតែងមានឥទ្ធិពលវិជ្ជមានទៅលើគុណភាពជីវិត (Un 2012)។ គោលនយោបាយសម្រាប់ការអភិវឌ្ឍកម្មវិធីសិក្សាឆ្នាំ២០០៥-០៩ បាននិយាយលំអិតពី ការផ្ដល់កម្មវិធីសិក្សាសម្រាប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ និងបឋមភូមិ ក្នុងគោលដៅ "បង្កើនទេពកោសល្យ និងសមត្ថភាពសិស្សទាំងអស់ឲ្យបានពេញលេញ ដើម្បីក្លាយជាពលរដ្ឋមានសមត្ថភាព ជាមួយនឹងការរីកលូតលាស់ស្របគ្នា និងមានតុល្យភាព ផ្នែកបញ្ញា ស្មារតី ចិត្តសាស្ត្រ និងរាងកាយ" (MOEYS 2004, 4)។ ដោយឡែក កម្មវិធីសិក្សាថ្នាក់មធ្យមសិក្សាទុតិយភូមិ មានគោលដៅផ្ដល់ឲ្យសិស្សនូវ គ្រឹះដ៏រឹងមាំផ្នែក

អក្សរសាស្ត្រខ្មែរនិងគណិតវិទ្យា ការយល់ដឹងពីអត្តសញ្ញាណជាតិ និងបំណិនជីវិតដើម្បីអាចចូលរួមក្នុងជីវិតសហគមន៍ ព្រមទាំងមូលដ្ឋានគ្រឹះផ្នែកវិទ្យាសាស្ត្រទូទៅ និងវិទ្យាសាស្ត្រពិត និងជំនាញផ្នែកភាសាបរទេស (UNESCO 2008, 11)។ នាបច្ចុប្បន្ន ក្រសួងអប់រំ យុវជន និងកីឡា កំពុងបង្កើតក្របខ័ណ្ឌថ្មីៗនៃកម្មវិធីសិក្សាថ្នាក់ជាតិសម្រាប់ការអប់រំទូទៅនិងផ្នែកបច្ចេកទេស ដែលគ្រោងនឹងផ្សាយចេញនៅចុងឆ្នាំ២០១៦។

ការស្រាវជ្រាវនានា បានបញ្ជាក់ពីសារៈសំខាន់នៃកំណែទម្រង់កម្មវិធីសិក្សា។ ដោយឡែក សព្វថ្ងៃនៅតែឃើញមានចន្លោះប្រហោងជាច្រើន រវាងគោលនយោបាយកម្មវិធីសិក្សា នឹងដំណើរការជាក់ស្តែងនៅក្នុងថ្នាក់រៀន។ សៀវភៅសិក្សាដែលជាធនធានស្នូលសម្រាប់ការបង្រៀន និងការរៀន ជាឧទាហរណ៍ជាក់ស្តែងមួយ។ ក្នុងការវិភាគលើខ្លឹមសារសៀវភៅសិក្សាសម្រាប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ ជាពិសេស ផ្នែកគណិតវិទ្យា និងវិទ្យាសាស្ត្រ លោក Un (2014) បានចោទសំណួរជាច្រើនពីគុណភាព និងប្រសិទ្ធភាពនៃសម្ភារបង្រៀនទាំងនោះ។ ក្រៅពីកង្វះខាតផ្នែករូបវន្ត សៀវភៅសិក្សាមានទិសដៅសម្រាប់តែបណ្តុះការគិតរបស់សិស្សក្នុងកម្រិតទាបប៉ុណ្ណោះ រីឯវិធីសាស្ត្របង្រៀនវិញ ក៏មិនបានផ្តល់ឲ្យសិស្សនូវជំនាញដែលអាចរកការងារបានដូចជា ការគិតបែបវិភាគ ការធ្វើការងារជាក្រុម និងការដោះស្រាយបញ្ហាដែរ។ ដោយមូលហេតុនេះ សមត្ថភាពសិស្សនៅតែមិនអាចបំពេញបានតាមតម្រូវការរបស់និយោជក ហើយការសិក្សាជាច្រើនបានបញ្ជាក់ដូចគ្នាពី ភាពមិនស៊ីគ្នារវាងជំនាញរបស់សិស្សមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ នឹងតម្រូវការរបស់និយោជក (ADB and ILO 2015; Khieng et al. 2015) ។ ដើម្បីកាត់បន្ថយបញ្ហាកង្វះខាតជំនាញ Davis (2005 cited in Nou 2015) បានបញ្ជាក់ពី តម្រូវការធ្វើស្តង់ដានីយកម្មការអប់រំថ្នាក់មធ្យមសិក្សា និងការគិតគូរឡើងវិញក្នុងការរៀបចំកម្មវិធីសិក្សា។

ដោយសារមានបញ្ហាប្រឈមទាំងនេះ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP) ឆ្នាំ២០១៤-១៨ បានបញ្ជាក់លំអិតពី កម្មវិធីអភិវឌ្ឍន៍សម្ភារបង្រៀននិងរៀនដ៏មាំទាំមួយ សំដៅកែលំអការអប់រំថ្នាក់មធ្យមសិក្សា និងថ្នាក់បច្ចេកទេស មានជាអាទិ៍ ការអភិវឌ្ឍកម្មវិធីសិក្សា ការផលិតនិងចែកចាយសៀវភៅសិក្សាគ្រប់មុខវិជ្ជាទៅតាមសាលាចំណេះទូទៅ និងការបង្កើតប្រព័ន្ធវាយតម្លៃមានស្តង់ដារច្បាស់លាស់សម្រាប់មុខវិជ្ជានីមួយៗ។

ទិដ្ឋភាពសំខាន់ពីរ ក្នុងវិស័យអប់រំដែលមិនសូវមានការស្រាវជ្រាវលើ គឺ ១) ការផ្លាស់ប្តូរពីគំនិតថា "គ្រូបង្រៀនជាឃ្លាំងចំណេះដឹង" ទៅជា "គ្រូបង្រៀនជាអ្នកបង្ហាត់បង្ហាញការរៀនសូត្រ" ហើយនិង ២) ការទាញយកអត្ថប្រយោជន៍ពីវគ្គសិក្សាតាមប្រព័ន្ធអ៊ិនធឺណិត (MOOCs) ដោយមិនមានការចំណាយអ្វី។ ការសិក្សាថ្មីៗមួយចំនួនបានពិភាក្សាពីតម្រូវការឲ្យ គ្រូបង្រៀនធ្វើការលើកទឹកចិត្តសិស្សឲ្យរៀនហួសពីសៀវភៅសិក្សា និងស្វែងរកចំណេះដឹងបន្ថែម (Ros and Chhem 2015; Chong 2013)។ ចំណុចនេះទាមទារការរៀបចំ វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈសម្រាប់គ្រូបង្រៀន អ្នកបង្ហាត់បង្ហាញការរៀនសូត្រ និងអ្នកជួយណែនាំទាំងឡាយ ដើម្បីផ្តល់នូវជំនាញដ៏ចាំបាច់មួយចំនួនសម្រាប់ការបង្រៀន និងជំរុញសិស្សឲ្យប្រើប្រាស់កម្មវិធី MOOC (Ros and Chhem 2015) ព្រោះបដិវត្តន៍ឌីជីថលកំពុងកែប្រែយ៉ាងលឿននូវការអប់រំក្នុងពិភពលោក ក្នុងសតវត្សទី២១ នេះ (Chhem 2016) ។

## *ការបង្រៀនគួរ*

ការស្រាវជ្រាវពីការបង្រៀនឯកជន ឬបង្រៀនគួរ ផ្តល់នូវគំនិតដ៏មានប្រយោជន៍អំពីទំហំ និងលក្ខណៈរបស់វា។ ការសិក្សាជាច្រើន (Bray 2007; Bray et al. 2016; Brehm and Silova 2014) បានពណ៌នាពី កំណើននិងតម្រូវការការរៀនជាឯកជនដែលពេលខ្លះសឹងតែដូចគ្នានឹងការរៀននៅសាលារដ្ឋដែរ ពីព្រោះការបង្រៀនគឺធ្វើឡើងដោយគ្រូដដែល ហើយពួកគាត់ប្រើប្រាស់កម្មវិធីសិក្សាដូចគ្នានឹងសាលារដ្ឋដែរ។ Brehm and Silova (2014) បានរាយការណ៍ថា ប្រជាជនទូទៅមើលឃើញការបង្រៀនគួរនេះជា ការអប់រំបន្ថែមមួយសម្រាប់បំពេញកម្មវិធីសិក្សានៅតាមសាលារដ្ឋ ដែលពួកគាត់គិតថានៅមានភាពមិនគ្រប់គ្រាន់ពោលគឺ សាលារដ្ឋផ្តល់នូវចំណេះដឹងជាទ្រឹស្តី រីឯការបង្រៀនគួរផ្តល់នូវការអនុវត្តទ្រឹស្តីជាក់ស្តែង។ ដោយផ្អែកលើខ្សែភាពយន្តនិងឯកសារស្តីពីប្រទេសកម្ពុជា ឥណ្ឌា និងទួរគី លោក Kobakhidze (2015) បានសង្កត់ធ្ងន់ពីបែបបទជាសាកលដែលការអប់រំនៅតាមសាលារដ្ឋអាចលាក់បំបាំងការពិត គឺគ្រួសារមានចំណូលទាប បានតស៊ូយ៉ាងលំបាកដើម្បីបង់ថ្លៃការរៀនជាឯកជន។

អ្នកប្រាជ្ញមួយចំនួន បានលើកបង្ហាញពីគុណសម្បត្តិ និងគុណវិបត្តិនៃការបង្រៀនគួរ។ ជាគុណសម្បត្តិ គេយល់ថា ការបង្រៀននេះជួយ ១) សិស្សដែលរៀនយឺតឲ្យរៀនទាន់សិស្សឯទៀត ២) សិស្សដែលពូកែស្រាប់ឲ្យរៀនកាន់តែពូកែថែមទៀត និង ៣) ធ្វើឲ្យសិស្សផ្តោតលើការសិក្សា ជាជាងដើរលេង ប្រើប្រាស់ថ្នាំញៀន ឬឆាប់មានទំនាក់ទំនងផ្លូវភេទជាដើម (Bray and Lykins 2012; Dawson 2011, 2010)។ ជាគុណវិបត្តិ ការបង្រៀនគួរអាចបង្កើតវិសមភាពក្នុងការអប់រំ ពីព្រោះគ្រួសារដែលមានជីវភាពធូរធារ អាចមានលទ្ធភាពបង់ថ្លៃរៀនសូត្រ និងរកបានគ្រូល្អជាងគ្រួសារក្រីក្រ។ ម្យ៉ាងទៀត ការបង្រៀនឯកជនអាចប៉ះពាល់ដល់ការងារ និងគុណភាពបង្រៀនរបស់គ្រូក្នុងសាលាធម្មតា ហើយការរៀនគួរបន្ថែម វាកាត់បន្ថយពេលសម្រាកលំហែ និងពេលវេលានៅជាមួយក្រុមគ្រួសាររបស់សិស្ស (Bray and Lykins 2012: Kobakhidze 2015)។ ម៉្យាងវិញទៀត ការបង្រៀនឯកជន ក៏ជាបន្ទុកហិរញ្ញវត្ថុមួយលើគ្រួសារមានចំណូលទាបដែរ (Bray et al. 2016)។

ការប្រៀបធៀបលំនាំនៃការបង្រៀនគួរក្នុងប្រទេសចំនួន ៣០ នៅអាស៊ី បង្ហាញថា ការបង្រៀនឯកជន មានប្រវត្តិយូរលង់ណាស់មកហើយ ហើយវាមានការប្រែប្រួលខុសៗគ្នាពីប្រទេសមួយទៅប្រទេសមួយ ទៅតាមកត្តាសេដ្ឋកិច្ច និងវប្បធម៌ខុសៗគ្នា (Bray and Lykins 2012)។ ជាទូទៅ ការបង្រៀនឯកជន អាចរួមចំណែកកែលំអលទ្ធផលសិក្សា ប៉ុន្តែវាក៏អាចប៉ះពាល់ដល់កត្តាសំខាន់ៗផ្សេងទៀត ដូចជា សុខភាពរាងកាយ សីលធម៌ និងភាព

ជាពលរដ្ឋមានទំនួលខុសត្រូវ។ ទោះបីមិនមានភស្តុតាងបង្ហាញច្បាស់ថា ការបង្រៀនឯកជនអាចជួយកែលំអលទ្ធផលសិក្សាក្តី ក៏ឪពុកម្តាយខ្លះជឿថា វាបានជួយពិតមែន (Bray et al. 2016)។ សរុបមក ការបង្រៀនឯកជន និងសកម្មភាពអប់រំបន្ថែម ហាក់ដូចកំពុងរីកដុះដាល ហើយក្លាយជាសកម្មភាពស្របច្បាប់ក្នុងប្រទេសជាច្រើន (Mori and Baker 2010) ។

### *កម្មវិធីសុខភាពរបស់សាលារៀន*

ការសិក្សាមួយចំនួនបានបង្ហាញពីតួនាទីនៃ ការស្រាវជ្រាវពីសុខភាពក្នុងផ្នែកនានានៃវិស័យអប់រំ រួមមាន សុខមាលភាពផ្លូវកាយនិងផ្លូវចិត្ត បំណិនជីវិត និងសុខភាពផ្លូវភេទ។ ការស្រាវជ្រាវពីឥទ្ធិពលនៃការប៉ះពាល់ជាតិពុលអាសេនិក ក្នុងចំណោមសិស្សវិទ្យាល័យនៅខេត្តកណ្តាល បានបញ្ជាក់ថា ជាតិពុលនេះអាចប៉ះពាល់ដល់ប្រព័ន្ធសរសៃប្រសាទ (arsenic neurotoxicity) (Vibol, Hashim and Sarmani 2015)។ ការសិក្សាស្រដៀងគ្នាមួយទៀតបញ្ជាក់ថា ការផ្គត់ផ្គង់ទឹកស្អាតនៅតាមសាលារៀនបានកាត់បន្ថយអត្រាអវត្តមាន និងអត្រាបោះបង់ការសិក្សា (Hunter et al. 2014)។

ការស្រាវជ្រាវពី សុខភាពផ្លូវភេទរបស់សិស្សថ្នាក់មធ្យមសិក្សា កម្រមានណាស់។ Yi et al. (2010) បានសិក្សាពីតួនាទីនៃកត្តាហានិភ័យ និងកត្តាការពារនៅក្នុងទម្លាប់រួមភេទដោយប្រថុយប្រថានរបស់សិស្សមធ្យមសិក្សា អាយុពី ១៤ ទៅ ២០ឆ្នាំ។ ក្នុងចំណោមសិស្ស ១០៤៩នាក់ មាន ១២% រាយការណ៍ថាខ្លួនមានទំនាក់ទំនងផ្លូវភេទក្នុងអំឡុងពេល ៣ខែកន្លងមក ហើយក្នុងនោះ ៣០% មានដៃគូច្រើនជាងម្នាក់ និង ៥០% មិនបានប្រើស្រោមអនាម័យ។ ដោយផ្អែកលើចម្លើយរបស់សិស្សប្រុសដែលបានចូលរួមក្នុងការស្រាវជ្រាវនេះ កត្តានាំឲ្យមានទម្លាប់រួមភេទដោយប្រថុយប្រថាននេះ តែងជាប់ទាក់ទងនឹងកត្តាគ្រួសារមានប្រាក់ចំណូលខ្ពស់ សម្ពាធពីមិត្តភក្តិ ការប្រើប្រាស់គ្រឿងញៀន ការធ្លាប់ឃើញអំពើហិង្សាក្នុងសហគមន៍ និងការទទួលបានការគាំទ្រកម្រិតទាបពីក្រុមគ្រួសារ ។

លទ្ធផលស្រាវជ្រាវ បានបង្ហាញជាថ្មីពីភាពបន្ទាន់នៃការអប់រំផ្លូវភេទដែលកំពុងឈានទៅដល់ ការរៀនតាមប្រព័ន្ធអ៊ិនធឺណិត។ គំនិតផ្តួចផ្តើមការរៀនតាមប្រព័ន្ធអ៊ិនធឺណិត (E-learning) សម្រាប់ការអប់រំផ្លូវភេទដល់សិស្សវិទ្យាល័យនេះ ត្រូវបានសាកល្បងក្នុងអនុវិទ្យាល័យ និងវិទ្យាល័យចំនួន ២៤ ហើយការស្រាវជ្រាវនេះ ក៏ត្រូវបានពង្រីកបន្ថែមទៀតដែរ (Tolson 2014)។ ម្យ៉ាងទៀត ការយល់ដឹងពីទំនោរផ្នែកផ្លូវភេទ និងផលប៉ះពាល់នៃការរើសអើងក្នុងសាលារៀនទៅលើ សិស្សដែលគេស្គាល់ថាជាអ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ ឬអ្នកកែភេទ (lesbian, gay, bisexual or transgender: LGBT) នៅមានកង្វះខាតជាខ្លាំង ដូចមានបង្ហាញក្នុងការសិក្សាថ្មីមួយស្តីពីការសំឡុតជាញឹកញយទៅលើយុវជន LGBT ក្នុងសាលារៀននៅកម្ពុជា (CCHR 2015)។

បញ្ហាផ្លូវចិត្ត និងផ្លូវអារម្មណ៍ក្នុងចំណោមយុវជនវ័យក្មេង ជាក្តីបារម្ភដ៏ធំមួយ។ គម្រោងស្រាវជ្រាវពីសុខភាពផ្លូវចិត្តមួយចំនួនដែលបានលើកមកសិក្សាក្នុងអត្ថបទនេះ បានផ្តោតលើកត្តាហានិភ័យនៃការធ្វើអត្តឃាត និងការរាលដាលនៃអត្តឃាតកម្ម។ ការសិក្សាមួយដែលពិនិត្យពីទំនាក់ទំនងរវាង ការផុសគំនិត និងទម្លាប់ធ្វើអត្តឃាតក្នុងស្រទាប់យុវជន ជាមួយនឹង អាកប្បកិរិយាសង្គម ប្រព័ន្ធផ្សព្វផ្សាយ និងសាសនា បានកត់សំគាល់ពីបែបបទដែលប្រព័ន្ធផ្សព្វផ្សាយនិងការបង្រៀនតាមផ្លូវសាសនា បានផ្តល់ព័ត៌មានមិនច្បាស់លាស់ និងមិនជាក់លាក់អំពីភាពតានតឹងចិត្តនឹងសង្គម (Psychosocial stress) និងការគិតចង់សម្លាប់ខ្លួន (Jegannathan, Kullgren and Dahlblom 2015)។ ជាដំណោះស្រាយ ការសិក្សានេះ បានផ្តល់យោបល់ឲ្យបង្កើត កម្មវិធីទប់ស្កាត់ការធ្វើអត្តឃាតនៅតាមសាលារៀន និង កម្មវិធីបណ្តុះបណ្តាលអ្នកប្រឹក្សាយោបល់នៅតាមសាលារៀន ដើម្បីបង្កើនចំណេះដឹងឲ្យកាន់តែធំទូលាយពីបញ្ហាសង្គម អត្តសញ្ញាណផ្នែកយេនឌ័រ សាសនា ក៏ដូចជាបញ្ហាក្នុងគ្រួសារ ដែលអាចជះឥទ្ធិពលមិនល្អទៅលើការសិក្សា និងការអភិវឌ្ឍខ្លួនរបស់សិស្ស។ ការសិក្សាស្រដៀងគ្នាមួយទៀត បានពិនិត្យពីការគិតចង់សម្លាប់ខ្លួនរបស់សិស្សចំនួន ៣២០នាក់ រៀននៅថ្នាក់ទី១០ និង១១ ក្នុងវិទ្យាល័យពីរនៅក្រុងតាខ្មៅ ហើយបានរកឃើញថា សិស្សប្រុសធ្លាប់មានគម្រោងសម្លាប់ខ្លួនញឹកញាប់ជាងសិស្សស្រី ប៉ុន្តែសិស្សស្រីធ្លាប់បានប៉ុនប៉ងសម្លាប់ខ្លួនញឹកញាប់ជាង សិស្សប្រុស (Jegannathan and Kullgren 2011)។

ការស្រាវជ្រាវអំពីក្មេងជំទង់ធ្លាប់ជួបនឹងអំពើហិង្សា បានរកឃើញថា សិស្ស ជាពិសេស សិស្សស្រីដែលធ្លាប់ជួបនឹងអំពើហិង្សាក្នុងគ្រួសារនិងសហគមន៍ តែងមានរោគសញ្ញាបាក់ទឹកចិត្តខ្លាំងច្រើនជាងគេ (Yi et al. 2013)។ ដូចនេះ យុទ្ធសាស្រ្តសម្រាប់បង្កើតសហគមន៍មានសុវត្ថិភាព និងគ្មានអំពើហិង្សា និងសម្រាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ អាចជួយកាត់បន្ថយបានច្រើននូវការបាក់ទឹកចិត្តក្នុងចំណោមយុវជន (Yi et al. 2013)។ ជាក់ស្តែង កម្មវិធីបំណិនជីវិតនៅវិទ្យាល័យពីរក្នុងក្រុងតាខ្មៅ បានជួយកែលំអសុខមាលភាពផ្លូវចិត្តរបស់សិស្ស ហើយបានកាត់បន្ថយទម្លាប់ប្រថុយគ្រោះថ្នាក់របស់ ក្មេងប្រុសជំទង់ (Jegannathan, Dahlblom and Kullgren 2014)។

### ការពិភាក្សា និងទិសដៅស្រាវជ្រាវនៅអនាគត

អត្ថបទនេះបានគូសបញ្ជាក់ពីគម្លាតដ៏ធំរវាង ការស្រាវជ្រាវគោលនយោបាយផ្នែកអប់រំ ជាមួយនឹង ដំណើរការអប់រំជាក់ស្តែងនៅតាមវិទ្យាល័យ។ពិតហើយមានការស្រាវជ្រាវជាច្រើនដែលត្រូវធ្វើជាបន្ទាន់ ប៉ុន្តែក្នុងនោះ យើងគួរយកចិត្តទុកដាក់ជាពិសេសលើ ៤ចំណុច៖ ១)ការបង្កើនគុណភាព ២) កម្មវិធីសិក្សានិងគរុកោសល្យ ៣) ការបង្រៀនគួរ និង ៤) ការចូលរួមក្នុងសង្គម ការអភិវឌ្ឍផ្លូវចិត្ត និងការសិក្សារបស់សិស្ស។

ការស្រាវជ្រាវ បានបញ្ជាក់បន្តទៀតថា កង្វះការអប់រំមានគុណភាព និងគ្រូបង្រៀនមានការបណ្តុះបណ្តាលត្រឹមត្រូវ (អ្នកពាក់ព័ន្ធសំខាន់ក្នុងការកែលំអការអប់រំ) ជាបញ្ហាប្រឈមធំជាងគេ។ ការវិភាគស៊ីជម្រៅបន្ថែម គួរពិនិត្យលើសំណួរគន្លឹះដូច

*តទៅទំព័រ ១៤*

មាននៅឡើយ។ លទ្ធផលនៃការសិក្សានេះ មានផលពាក់ព័ន្ធចម្បងៗពីរ។ ទី១ ការសិក្សាផ្តល់គំនិតថា អ្នកទ្រទ្រង់គម្រោងគួរវាយតម្លៃឡើងវិញពី កត្តាជំរុញការរេចរឹល និងបាត់បង់ព្រៃឈើដែលពួកគេកំពុងព្យាយាមដោះស្រាយ។ ទី២ ដើម្បីឲ្យគម្រោងរេដ+ ទទួលបានជោគជ័យ ត្រូវធានាថា បទបញ្ញត្តិ និងច្បាប់ទប់ស្កាត់ការកាប់ឈើខុសច្បាប់ ត្រូវបានពង្រឹងអនុវត្តន៍ជាបន្ទាន់។ កិច្ចការនេះទាមទារនូវ កិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពពីសំណាក់វិស័យសំខាន់ៗដទៃទៀត ដូចជា វិស័យថាមពល កសិកម្ម និងពាណិជ្ជកម្ម ព្រមទាំងការបង្កើតចំណងតភ្ជាប់ជាមួយសកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ចផ្អែកលើដីធ្លីផ្សេងៗទៀត។

## ឯកសារយោង


Angelsen, Arild. 2010. "Policies for Reduced Deforestation and their Impact on Agricultural Production." *Proceedings of the National Academy of Sciences of the United States of America* 107(46): 19639-19644.

CCBS (Climate, Community and Biodiversity Alliance). 2016. "Reduced Emissions from Deforestation and Degradation in Seima Protection Forest." www.climate-standards.org/ 2013/09/12/reduced-emissions-from-deforestation-and-degradation-in-seima-protection-forest-2/.

FA & WCS. 2011. *Overview of the Seima Protection Forest REDD Project*. Phnom Penh: Forestry Administration and Wildlife Conservation Society Cambodia Program.

Nguon Pheakkdey. 2014. *REDD+ Feasibility Assessment for Community Protected Areas in Cambodia*. Phnom Penh: Ministry of Environment, Adaptation Fund and United Nations Environment Programme.

Nguon Pheakkdey and  Chhun Delux. 2015. *Background Document of Cambodia's National REDD+ Strategy*. Phnom Penh: REDD+ Taskforce Secretariat.

Nguon Pheakkdey and Dominik Kulakowski. 2013. "Natural Forest Disturbances and the Design of REDD+ Initiative." *Environmental Science and Policy* 33(4): 332-345.

Peskett, Leo, and Kimberly Todd. 2013. "Putting REDD+ Safeguards and Safeguard Information Systems Into Practice." UN-REDD Programme Policy Brief 03. Geneva: UN-REDD Programme Secretariat.

Roe, Stephanie, Charlotte Streck, Luke Pritchard and John Costenbader. 2013. *Safeguards in REDD+ and Forest Carbon Standards: A Review of Social, Environmental and Procedural Concepts and Application*. Washington, DC: Climate Focus.

RTS (REDD Taskforce Secretariat). 2015. *National REDD+ Strategy's Work Plan*. Phnom Penh: Cambodia REDD+ Tasforce Secretariat

UNFCCC (United Nations Framework Convention on Climate Change). 2013. *Report of the Conference of the Parties on its Nineteenth Session*. Warsaw, Poland: UNFCCC.

UNFCCC. 2014. "Glossary of Climate Change Acronyms." http://unfccc.int/essential_background/glossary/items/3666.php#R.

UN-REDD Programme. 2015. "Journal 7: REDD+ Safeguards and Safeguard Information Systems." *REDD+ Academy  Learning Journal*.


*តពីទំព័រ ៥* **វិទ្យាល័យនៅកម្ពុជា...**

តទៅ៖ តើគួរអនុវត្តវិធានការគោលនយោបាយអ្វីខ្លះដើម្បីបង្កើនគុណភាពអប់រំថ្នាក់មធ្យមសិក្សា? និង តើកត្តាសង្គមអ្វីខ្លះដែលជះឥទ្ធិពលលើការសិក្សារបស់សិស្ស និងការអនុវត្តរបស់គ្រូនៅក្នុងថ្នាក់រៀន?

ទោះបីមានការប្រឹងប្រែងច្រើនហើយក្តី ក៏កំណែទម្រង់កម្មវិធីសិក្សាមិនទាន់បានប្រណិតទេ ហើយភាពមិនស៊ីគ្នារវាងការសិក្សារបស់សិស្ស និងជំនាញដែលនិយោជកត្រូវការ នៅតែជាកង្វល់ដ៏ធំ។ ការអង្កេតបន្ថែម គួរផ្តោតលើសំណួរស្រាវជ្រាវដូចតទៅ៖ តើមានជម្រើសគោលនយោបាយអ្វីខ្លះ សម្រាប់បន្តការពិនិត្យឡើងវិញ និងការធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សា ដើម្បីឲ្យវានៅតែសមស្របតាមតម្រូវការ? តើកម្ពុជាអាចរក្សាតុល្យភាពបានល្អប៉ុណ្ណា រវាងការធ្វើស្តង់ដានីយកម្ម និងការកែសម្រួលតាមករណីនីមួយៗ (Customization) នៃការអភិវឌ្ឍកម្មវិធីសិក្សា? តើដំណើរការដាក់បញ្ចូល ការអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ (TVET) ទៅក្នុងថ្នាក់មធ្យមសិក្សាទុតិយភូមិ ឈានដល់ដំណាក់កាលណាទៅហើយ? តើកត្តាអ្វីខ្លះដែលជះឥទ្ធិពលលើការដាក់បញ្ចូល TVET ទៅក្នុងថ្នាក់មធ្យមសិក្សាទុតិយភូមិ? តើការដាក់បញ្ចូលវិធីសាស្រ្តបង្រៀនមានអន្តរកម្មច្រើន វាមានវិសាលភាពប៉ុណ្ណា? តើធ្វើយ៉ាងណាដើម្បីផ្សារភ្ជាប់ការបង្រៀនតាមបែបបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT) ទៅនឹងវគ្គសិក្សាតាមប្រព័ន្ធអ៊ិនធឺណិត ឲ្យមានប្រសិទ្ធភាពខ្ពស់បំផុត? និង តើគ្រូបង្រៀនកម្ពុជា ត្រូវកសាងសមត្ថភាពឲ្យបានដល់កម្រិតណា ដើម្បីអាចអនុវត្តវិធីសាស្រ្តបង្រៀនមានអន្តរកម្មនេះបាន?

ដើម្បីអាចយល់កាន់តែច្បាស់ពីគុណសម្បត្តិ និងគុណវិបត្តិនៃការបង្រៀននិងរៀនគួរ ការស្រាវជ្រាវទៅអនាគតគួរផ្តោតលើសំណួរ ដូចជា៖ តើផលប៉ះពាល់ជាក់ស្តែងនៃការបង្រៀនឯកជនទៅលើគុណភាពនៃការបង្រៀន កម្មវិធីសិក្សា លទ្ធផលសិក្សា និងសមភាពក្នុងការអប់រំ មានអ្វីខ្លះ? និង តើការបង្រៀនគួរនៅកម្ពុជានាពេលបច្ចុប្បន្ន មានស្ថានភាព និងនិន្នាការយ៉ាងដូចម្តេច? ប្រធានបទស្រាវជ្រាវក្នុងផ្នែកនេះ រួមមាន ១) វិសមភាពនៃការអប់រំបង្កឡើងដោយការបង្រៀនឯកជន ២) ការយល់ឃើញរបស់សិស្ស ឪពុកម្តាយ និងគ្រូបង្រៀន លើការបង្រៀនគួរ និង ៣) តម្លៃនៃការបង្រៀនគួរ។ ការស្រាវជ្រាវទៅអនាគតស្តីពីការបង្រៀនឯកជន ក៏ត្រូវយកចិត្តទុកដាក់លើភាពខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ និងវប្បធម៌ផ្សេងៗដែរ (Bray 2010)។

កម្មវិធីសុខភាពរបស់សាលា សំខាន់ខ្លាំងណាស់សម្រាប់ធានាឲ្យបាននូវជោគជ័យនៃការសិក្សា ក៏ដូចជា សុខភាពផ្នែករាងកាយ ផ្លូវចិត្ត បញ្ញា និងសង្គមរបស់សិស្ស។ ការសិក្សាមួយចំនួនតូចដែលបានធ្វើឡើងកន្លងមក មានទំហំតូច ហើយផ្តោតតែលើតំបន់ទីក្រុងប៉ុណ្ណោះ។ ដូច្នេះការស្រាវជ្រាវទៅអនាគតលើបញ្ហាសុខភាពក្នុងវិស័យអប់រំ គួរពង្រីកទៅដល់តំបន់ជនបទ ហើយការស្រាវជ្រាវដើម្បីធ្វើសកម្មភាព អាចនឹងផ្តល់នូវករណីសិក្សាដ៏មានប្រយោជន៍ជាច្រើនបន្ថែមទៀត។

សរុបមក ការស្រាវជ្រាវ គួរធ្វើឡើងឲ្យបានទៀងទាត់ដើម្បីផ្តល់ភស្តុតាង ដែលអាចរួមចំណែកដល់ការកសាងសមត្ថភាពធនធានមនុស្ស តាមរយៈកម្មវិធីសិក្សាដែលមានប្រសិទ្ធភាព គ្រូបង្រៀនដែលមានសមត្ថភាព និងកម្មវិធីអប់រំដែលសមស្របតាមតម្រូវការ។ ថវិកាជាតិ ក៏គួរមានចែកសម្រាប់ជួយទ្រទ្រង់ដល់ការសិក្សាស្រាវជ្រាវផ្នែកអប់រំ ជាពិសេស ការអប់រំនៅកម្រិតមធ្យមសិក្សាទុតិយភូមិដែរ។

## ឯកសារយោងមាននៅក្នុងអត្ថបទជាភាសាអង់គ្លេស